## រៀបចំកសាងច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១ ខែវិច្ឆិកាឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញការចាំបាច់របស់ក្រសួង

### សំរេច

**ប្រការ ១** ៖ បង្កើតគណៈកម្មការសំរបសំរួល កិច្ចការរៀបចំ កសាង ច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **ជា ប៉េងឈាង** អនុរដ្ឋលេខាធិការ ប្រធាន

២-លោក **ម៉ែន ម៉ាណា** នាយកខុទ្ទកាល័យ សមាជិក

៣-លោក **ប្រាក់ ឡេង** ប្រធានមន្ទីរ សមាជិក

៤-លោក **លិម ប៊ុនហៃ** អនុប្រធាននាយកដ្ឋានថវិកា សមាជិក

**ប្រការ ២** ៖ គណៈកម្មការមានភារកិច្ច សំរបសំរួល រៀបចំ,កសាង ច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ អោយបានសមស្របតាមប្រតិទិន ដើម្បីសុំការអនុម័តពីរដ្ឋសភា នៅចុងឆ្នាំ ១៩៩៤ ខាងមុខនេះ ។

**ប្រការ ៣** ៖ លោកនាយកខុទ្ទកាល័យ លោកប្រធានមន្ទីរ លោកប្រធាននាយកដ្ឋានបុគ្គលិក និងអង្គភាពដែលពាក់ព័ន្ធព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ហត្ថលេខា និង ត្រា**

**សម រង្ស៊ី**

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៤*

## ប្រកាសលេខ ១៤៧ ប្រក.សហវ

## ស្តីពីអត្តសញ្ញាណកម្មនៃសហគ្រាសដាប់ពន្ធលើប្រាក់ចំណេញ និងអាករលើផលរបរតាមរបបពិតប្រាកដ

ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នៃព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញប្រកាសលេខ ០១៨ ប្រក.សហវ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ របស់ទីស្តីការ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីអត្តសញ្ញាណកម្មនៃអ្នកជាប់ពន្ធលើប្រាក់ ចំណេញ និង អាករលើផលរបរតាមរបបពិត ប្រាជក ។

**សំរេច**

**ប្រការ ១ :** បទបញ្ញត្តិទាំងឡាយនៃប្រកាសលេខ ០១៨ ប្រក.សហវ ដូចបានយោងខាងលើត្រូវលុប ចោល និងត្រូវជំនួសដោយបទបញ្ញត្តិនៃប្រកាសនេះ ។

**ប្រការ ២ :** ត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃការកំណត់ពន្ធតាមរបបពិតប្រាកដ :

១- សហគ្រាសលក់ដូរផលិតផលនានាក្នុងសភាពដើម ឬ កែច្នៃហើយដែលមានផលរបរប្រចាំឆ្នាំដោយគិត បញ្ចូលទាំងអាករផងមានចំនួនលើសពី ៥០០.០០០.០០០ រៀល

២- សហគ្រាសធ្វើសេវាកម្ម ដែលមានផលរបរប្រចាំឆ្នាំ ដោយគិតបញ្ចូលទាំងអាករផង មានចំនួនលើសពី ២៥០.០០០.០០០ រៀល ។

៣- សហគ្រាសលក់ដូចផលិតផលនានាផង និង ធ្វើសេវាកម្មផង ដែលមានផលរបរប្រចាំ ឆ្នាំសរុបដោយគិតបញ្ចូលទាំងអាករផង មានចំនួនលើសពី ៥០០.០០០.០០០ រៀល ឬ តិចជាងចំនួននេះ ប្រសិនបើផលរបរបានមកពីការធ្វើសេវា កម្មមានចំនួនលើសពី ២៥០.០០០.០០០ រៀល ។

**ប្រការ ៣ :** ចំពោះករណីចាប់ផ្តើម ឬ បញ្ឈប់សកម្មភាពអាជីវកម្មក្នុងកំឡុងពេលណាមួយក្នុងឆ្នាំ គឺរិតផលរបរដែលបានកំណត់ក្នុងប្រការ ២ ខាងលើត្រូវបានបន្ថយដោយគិតសមាមាត្រ ទៅនឹងពេលវេលាដែលបានកន្លងផុតទៅ ដើម្បីកំណត់ របបកំណត់ពន្ធដែលត្រូវអនុវត្ត ។

**ប្រការ ៤ :** ត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃការកំណត់ពន្ធតាមរបបពិតប្រាកដ ដោយមិនគិតពីផលរបរប្រចាំឆ្នាំ និង ចាប់ពីពេលចាប់ផ្តើមសកម្មភាព គឺ :

១_ សហគ្រាសដែលបានធ្វើអាជីវកម្ម ក្រោមទ្រង់ទ្រាយជាក្រុមហ៊ុនបុគ្គល ឬ ក្រុមហ៊ុនដើមទុនសហគ្រាសសាធារណៈ និង រាល់ក្រុមពួកផ្សេងៗ ដែលមានចរិតលក្ខណៈជាសាធារណៈដែលធ្វើ សកម្មភាពស្ថិតក្នុងដែនអនុវត្ត នៃ ពន្ធលើប្រាក់ចំណេញ និង អាករលើផលរបរ

២_ សហគ្រាសដែលបានធ្វើអាជីវកម្ម នាំចេញ នាំចូល ជាចំបង និង ជានិច្ចជាកាលដើម្បីជាប្រយោជន៍របស់ ខ្លួនផ្ទាល់ ឬ ដើម្បីជាប្រយោជន៍របស់អ្នកផ្សេង

៣_ សហគ្រាសដែលបានទទួលធ្វើ ឬ ផ្គត់ផ្គង់អ្វីមួយ ឬ ក៏ច្រើន ជូនអង្គការសាធារណៈហើយដែលមានចំនួនទឹកប្រាក់ប្រចាំឆ្នាំសរុបទាំងអស់លើសពី ១២៥.០០០.០០០.០០០ រៀល

៤_ សហគ្រាសដែលបានទទួលគុណប្រយោជន៍អំពីបទបញ្ញត្តិទាំង ឡាយនៃច្បាប់ស្តីពី វិនិយោគនៃកម្ពុជា

៥_ សហគ្រាសដែលបានកំណត់ក្នុងមាត្រា ៤៥ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដូចបានយោងខាងលើ

**ប្រការ ៥ :** ប្រកាសនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៤ មក ។

ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**

***

*រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៤*

## ប្រកាសលេខ ១៤៨ ប្រក.សហវ

## ស្តីពីការកំណត់ពន្ធលើប្រាក់ចំណេញអំពីអាជីវកម្មចិញ្ចឹមមច្ឆា

ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាលកម្ពុជា